ទីស្ដីការក្រសួងយុត្តិធម៌
លេខ ០៤ ព្រទ.ស.ច-៩៧

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## សារាចរ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**សូមជម្រាបមក**

**លោក ប្រធានតុលាការកំពូល**
**លោក អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល**
**លោក ប្រធានសាលាឧទ្ធរណ៍**
**លោក ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**
**លោក ប្រធានតុលាការខេត្ត ក្រុង**
**លោក ព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង**
**លោក ប្រធានតុលាការយោធា**
**លោកព្រះរាជអជ្ញាអមតុលាការយោធា**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការឃុំខ្លួនពិរុទ្ធជនហួសចិរវេលាកំណត់នៃច្បាប់ ។

ខ្ញុំសូមជម្រាបអស់លោកជ្រាបថា ជាលើកទី៣ហើយដែលក្រសួងយុត្តិធម៌ចេញសារាចរណែនាំអស់លោក អំពីបញ្ហាដែលចែងក្នុងកម្មវត្ថុខាងលើនេះ ។

ខ្ញុំសូមចតចម្លងផ្ញើជាប់មកជាមួយនេះនូវសារាចរ២លើកមុន ចុះថ្ងៃទី៣១ ឧសភា ១៩៩៤ និង១៤ កុម្ភៈ ១៩៩៦ ដើម្បីអស់លោកចាប់អារម្មណ៍លើការណែនាំផ្ទួនៗ នេះ ។

ក្រសួងបានកត់សម្គាល់ឃើញថា នៅតែមានការឃុំខ្លួនពិរុទ្ធជនហួសចិរវេលាកំណត់នៃច្បាប់នៅតាមខេត្ត ក្រុង ជាពិសេសនៅរាជធានីភ្នំពេញតែម្ដង ។

ក្រសួងយុត្តិធម៌ទុកពេលជូនអស់លោកដោយអនុគ្រោះជាទីបំផុតរហូតដល់ពាក់កណ្ដាលឆ្នាំ១៩៩៧ នេះគឺ រហូតដល់ដំណាច់ខែមិថុនា ១៩៩៧ ដើម្បីបញ្ជូនសំណុំរឿងពិរុទ្ធជនដែលជាប់ឃុំជាបណ្ដោះអាសន្នយូរមកហើយទៅ ជំនុំជម្រះអោយអស់ កុំអោយមាននៅសល់ទៀត ។

ចាប់ពីខែកក្កដា១៩៩៧ទៅ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត ព្រមទាំងប្រធានតុលាការ ត្រូវទទួលវិន័យ ព្រមាន បើនៅមានពិរុទ្ធជនណាមួយឃុំខ្លួនហួសចិរវេលាកំណត់នៃច្បាប់ ។

ខ្ញុំសូមអស់លោកយកចិត្តទុកដាក់ខ្ពស់ក្នុងរឿងនេះ ដែលអាចនាំលោកទៅដល់ការទទួលខុសត្រូវតាមមាត្រា ៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ ឆ្នាំ ។

ទទួលបានសារាចរនេះ សូមអស់លោកប្រជុំគ្នាអោយអញ្ជើញនគរបាលយុត្តិធម៌អោយចូលរួមផង ដើម្បីចាត់ វិធានការណ៍យ៉ាងណាអោយចិរវេលាឃុំខ្លួនបណ្ដោះអាសន្ន ដែលកំណត់ក្នុងច្បាប់ជាធរមានគោរពបានដាច់ខាត ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

<u>ចម្លងជូន</u>
-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ
ជាព្រះរាជាធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-សម្ដេចនាយករដ្ឋមន្ត្រីទាំងពីរ នៃរាជរដ្ឋាភិបាល